ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៨៣០ អ.ក
ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១
សាលក្រមលេខៈ ៤៧ (ថ)
ចុះថ្ងៃទី២៦/មេសា/២០២២

-បានបើកកិច្ចពិភាក្សាដេញដោលជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**មេធាវី**

លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌៈ១៨៣០ អ.ក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ហៅ ស្នា ភេទប្រុស កើតឆ្នាំ១៩៨៩ ជនជាតិខ្មែរ មុខរបរ ជាងសំណង់ ទីកន្លែងកំណើតភូមិ [redacted] ខេត្តពោធិ៍សាត់ លំនៅបច្ចុប្បន្នស្នាក់នៅបន្ទប់ជួលភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] គប (ស្លាប់) ម្ដាយឈ្មោះ ថា (រស់) ប្រពន្ធឈ្មោះ [redacted] ធារី ជានីតិជន ទោសពីមុន គ្មាន កម្រិតវប្បធម៌ រៀនថ្នាក់ទី០៧ថ្មី (ឃុំខ្លួន ថ្ងៃទី០១.១១.២០២១)

ជាប់ចោទពីបទៈ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលំភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-បានឃើញមាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រាបន្តបន្ទាប់។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ**

កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ ប្រជាពលរដ្ឋបានរាយការណ៍ជូនសមត្ថកិច្ចរដ្ឋបាលស្វាយរលំបានឃើញបុរសម្នាក់កំពុងជិះកង់ នៅខាងលិចរបងរោងចក្រម៉េងគុង ស្ថិតនៅភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដោយមានការសង្ស័យសមត្ថកិច្ចក៏បានឃាត់ខ្លួន និងឆែកឆេរ រកឃើញថ្នាំញៀន ពណ៌សថ្លាសង្ស័យជាថ្នាំញៀន ចំនួន ០១ កញ្ចាប់ធំ។ បន្ទាប់មកសមត្ថកិច្ចក៏បានធ្វើការនាំខ្លួនជនសង្ស័យខាងលើទៅដល់បន្ទប់ជួល ហើយដោះខោអាវជនសង្ស័យចេញ ក៏ឃើញកាបូបក្រវ៉ាត់នឹងចង្កេះរបស់ជនសង្ស័យ រកឃើញថ្នាំ ចំនួន ០២ កញ្ចាប់តូចបន្ថែមទៀត សមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនជនសង្ស័យរួម និងវត្ថុតាងមកកាន់ប៉ុស្ដិ៍តែម្ដង។ ជនសង្ស័យបានសារភាពថាថ្នាំញៀនដែលខ្លួនបានមក ខ្លួនទិញពីជនមិនស្គាល់ឈ្មោះដើម្បីយកមកប្រើប្រាស់ និងលក់បន្ត។

-ក្រោយពីបានធ្វើកិច្ចពិភាក្សាដេញដោល
-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យឯកសារនានានៅក្នុងសំណុំរឿង
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យ និងពិចារណាតាមផ្លូវច្បាប់រួចរាល់ហើយ

## សាលាដំបូងខេត្តកណ្តាល
## យល់ឃើញថា

១-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ចាន់រិទ្ធ ហៅស្នា តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ តាមការពិនិត្យភស្តុតាង និងឯកសារនានា ដែលមានក្នុងសំណុំរឿងឃើញថា ពិតជាមាន អង្គហេតុដែលតំណាងអយ្យការធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted]ចាន់រិទ្ធ ហៅ ស្នា ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពិតប្រាកដមែន។

២-ជនជាប់ឈ្មោះ [redacted] ចាន់រិទ្ធ ហៅ ស្នា ជានីតិជន ហើយជនជាប់ចោទមានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ចំពោះមុខច្បាប់ពោល គឺជនជាប់ចោទមិនមានសញ្ញាណណាមួយដែលបង្ហាញថា ជនជាប់ចោទមានសតិវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ ដែលជាហេតុមិននាំឱ្យមិនមានការមិនទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួននោះឡើយ។

៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ហៅ ស្នាៈ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ដែលបានឆ្លើយនៅក្នុងនីតិវិធីនៃកិច្ចពិភាក្សាដេញដោលថា ខ្លួនត្រូវគេចាប់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ ខ្លួនបានចេញពីធ្វើការរោងចក្រ គេឆែកខ្លួន ម៉ោងប្រហែល៥កន្លះល្ងាច កន្លែងហ្នឹងស្វាត់មានតែខ្លួនទេចេញតាមហ្នឹងក្រោយរោងចក្រ។ ពេលប៉ូលីសចាប់ឆែកកង់ឃើញមួយកញ្ចប់ ឆែកបន្ទប់ជួលឃើញសាច់ជូ។ ខ្លួនទទួលស្គាល់ថ្នាំញៀនតែមួយកញ្ចប់ដែលឆែកឃើញលើខ្លួន។

ជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ហៅ ស្នា ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល។ តាមចម្លើយរបស់ជនជាប់ដែលបានឆ្លើយពេលសវនាការ គ្រាន់តែជាការឆ្លើយដោះសារតែប៉ុណ្ណោះ តែបើតាមចម្លើយដែលជនជាប់ចោទបានឆ្លើយនៅមុខតំណាងអយ្យការ និងមន្ត្រីនគរបាលយុត្តិធម៌ថា គ្រឿងញៀនម៉ាទឹកកកចំនួនមួយកញ្ចប់ធំ ខ្លួនលាក់ទុកនៅក្រោមកែបកង់របស់ខ្លួនកំពុងជិះ និងគ្រឿងញៀនពីរកញ្ចប់តូចរកឃើញក្នុងខ្លួនរបស់ខ្លួន និងមួយកញ្ចប់ធំល្មមដែលរកឃើញក្នុងបន្ទប់ជារបស់ខ្លួនទាំងអស់ ដែលខ្លួនបានមកពីបុរសម្នាក់មិនស្គាល់ឈ្មោះ និងតាមចម្លើយរបស់សាក្សី ឈ្មោះ [redacted] ម៉ៅ និងឈ្មោះ[redacted] សារឿន និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌កំណត់ហេតុធ្វើតេស្តទឹកនោមលើជនជាប់ចោទ និងតាមការពិនិត្យភស្តុតាងនានាដែលមានក្នុងសំណុំរឿងគឺមានភាពស៊ីសង្វាក់គ្នា អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ[redacted]ចាន់រិទ្ធ គឺបានជួញដូរ និងប្រើប្រាសដោយខុសច្បាប់នូវសារធាតុញៀន ដូចនេះតុលាការយល់ថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធដែលមាននៅក្នុងអង្គហេតុខាងលើនេះ គឺជាជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

៤-យោងចំណុចទី ៣ នៃផ្នែកសំអាងហេតុនៃសាលក្រមនេះ ឃើញថា បច្ច័យទាំងនេះគឺកើតចេញ ពីអំពើរបស់ជនជាប់ចោទដោយផ្ទាល់ដែលតម្រូវឱ្យជនជាប់ចោទទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួន។

៥-ធាតុអត្តនោម័តរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ហៅ ស្នា ៖ តាមចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយនៅមុខតំណាងអយ្យការ និងមន្ត្រីនគរបាលយុត្តិធម៌ ចម្លើយរបស់សាក្សីជាមន្ត្រីនគរបាលយុត្តិធម៌ តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងវត្ថុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទពិតជាខ្លួនបានទិញថ្នាំញៀនពីជនមិនស្គាល់ឈ្មោះដើម្បីយកមកប្រើប្រាស់និងលក់បន្តពិតប្រាកដមែន។ សកម្មភាពទាំងនេះ គឺអាចបញ្ជាក់ពី ធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ជាអំពើមួយដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម និងប៉ះពាល់ដល់សន្តិសុខសង្គម ជាអំពើមួយដែលច្បាប់បញ្ញត្តិចែងថាជាអំពើ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ គប្បីតុលាការសម្រេចធ្វើការប្រកាសទោសឱ្យជនជាប់ចោទទទួលខុសត្រូវតាមបញ្ញត្តិនៃមាត្រាខាងលើ។

៧-មានធាតុផ្សំនៃបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសទៅលើជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-ការសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ក្រោយពីបានធ្វើកិច្ចពិភាក្សាដេញដោល ឃើញថា ជនជាប់ចោទបានសារភាពហើយ ដូចនេះតំណាងអយ្យការសូមឱ្យចៅក្រមជំនុំជម្រះតម្កល់បទចោទប្រកាន់លើជនជាប់ចោទទុកនៅដដែល និងសូមឱ្យចៅក្រមជំនុំជម្រះសម្រេចតាមច្បាប់។

តំណាងអយ្យការប្តឹងសុំ៖ តម្កល់បទចោទកាន់ទុកនៅដដែល និងសូមឱ្យចៅក្រមជំនុំជម្រះសម្រេចតាមច្បាប់។ ចំពោះការប្តឹងសុំរបស់តំណាងអយ្យការលើចំណុចនេះ តុលាការបានយល់ឃើញដូចមាននៅក្នុងចំណុចទី៣,៥, ៦, និងចំណុចទី៧ នៃផ្នែកសំអាងហេតុនៃសាលក្រមនេះ។

៩-វត្ថុចាប់យករួមមាន៖

៩-១ ម្សៅក្រាមសថ្លាសង្ស័យសារធាតុញៀនប្រភេទម៉ាទឹកកកចំនួន០៤ កញ្ចប់ (ធំល្មម ០២ និងតូច០២)មានទម្ងន់ ៩,៥១ក្រាម និងសម្ភារៈសម្រាប់ប្រើប្រាស់ថ្នាំញៀនមួយចំនួន។ វត្ថុចាប់យកទាំងនេះជាវត្ថុតាងនៃបទល្មើសខាងលើ គប្បីតុលាការសម្រេចរឹបអូសបំផ្លាញចោល។

៩-២ កង់ចំនួន ០១គ្រឿង ។ វត្ថុចាប់យកនេះ គឺជាវត្ថុតាងនៃបទល្មើសខាងលើ គប្បីតុលាការសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។

១០-មេធាវីការពារឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ បានសារភាពចំពោះមុខតុលាការ សូមឱ្យតុលាការបន្ធូរបន្ថយទោស ព្រោះបានសារភាពហើយ។ ចំពោះការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទត្រង់ចំណុចនេះ តុលាការបានយល់ឃើញដូចមាននៅក្នុងចំណុច ៣, ៥, ៦ និងចំណុច៧ នៃផ្នែកសំអាងហេតុនៃសាលក្រមនេះ។

១១-សំណូមពររបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ៖ សូមឱ្យតុលាការជួយបន្ធូរបន្ថយទោស។



Scanned with CamScanner

ចំពោះសំណូមពររបស់ជនជាប់ចោទដូចមានក្នុងចំណុចទី១០ នៃផ្នែកសំអាងហេតុនៃសាលក្រមនេះ តុលាការបានយល់ឃើញដូចមាននៅក្នុងចំណុចទី ៣,៥, ៦, និងចំណុចទី៧ នៃផ្នែកសំអាងហេតុនៃសាលក្រមនេះ។

**ហេតុដូចនេះសាលាដំបូងខេត្តកណ្តាល**
**វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសលើជនជាប់ចោទ ឈ្មោះ [redacted] ចាន់រិទ្ធ ហៅ ស្នា ភេទប្រុស អាយុ ៣២ឆ្នាំ ដែលមានសាវតារជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល **២(ពីរ)ឆ្នាំ និង១០(ដប់)ខែ** ពីបទៈ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុតាងរួមមានៈ

ក-ម្សៅក្រាមសថ្លាសង្ស័យសារធាតុញៀនប្រភេទម៉ាទឹកកកចំនួន០៤ កញ្ចប់ (ធំល្មម ០២ និងតូច០២)មានទម្ងន់៩,៥១ក្រាម និងសម្ភារៈសម្រាប់ប្រើប្រាស់ថ្នាំញៀនមួយចំនួន ត្រូវរឹបអូសបំផ្លាញចោល

ខ-កង់ចំនួន ០១គ្រឿង ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ហៅ ស្នា ។

-ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា៖ [redacted] | ហត្ថលេខា និងត្រា៖ [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ព្រហស្បតិ៍ ៨ កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

កណ្តាល ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner